សូមជម្រាបសួរ នេះគឺជាការពិពណ៌នាដែលនឹងនិយាយអំពីពេល
ដែលខ្ញុំនៅរៀននៅក្នុងសាលាបឋមសិក្សាមួយ ហើយសាលាបឋមសិក្សារបស់ខ្ញុំគឺ
ស្ថិតនៅក្នុងភូមិរបស់ខ្ញុំ ហើយនៅមិនឆ្ងាយពីផ្ទះរបស់ខ្ញុំប៉ុន្មានទេ។ គឺមានរយៈចំងាយប្រហែលជា
១០ នាទី បើយើងធ្វើដំណើរដោយថ្មើរជើង ហើយខ្ញុំគឺតែងតែដើរទៅសាលារៀន គឺ
ដើរពីផ្ទះទៅសាលារៀន ហើយដើរពីសាលារៀនមកផ្ទះវិញ ហើយចំណាយពេលគឺមិនយូរប៉ុន្មានទេ
គឺប្រហែលជា ១៥ នាទី ១០ នាទី ទៅ ១៥ នាទីតែប៉ុណ្ណោះ។ នៅក្នុងថ្នាក់ទី ១ ខ្ញុំរៀនថ្នាក់ទី ១
គឺរៀនជាមួយនឹងអ្នកគ្រូ អ្នកគ្រូនោះគឺជាម្ដាយរបស់ខ្ញុំ ហើយពេលដែលខ្ញុំបានឡើងទៅដល់ថ្នាក់ទី ២
គឺខ្ញុំរៀនជាមួយលោកគ្រូម្នាក់ អញ្ចឹងពាក្យថាអ្នកគ្រូគឺសំដៅទៅលើ គ្រូបង្រៀនស្រី
ហើយពាក្យថាលោកគ្រូគឺសំដៅទៅលើគ្រូបង្រៀនប្រុស។ ក្នុងថ្នាក់ទី២
ខ្ញុំបានរៀនជាមួយលោកគ្រូម្នាក់ ហើយក្នុងថ្នាក់ទី ២ នេះ
គឺខ្ញុំចាំបានថាមានព្រឹត្តិការណ៍កើតឡើងដែលខ្ញុំត្រូវលោកគ្រូវៃនឹងរំពាត់
ហើយគឺជាការទូទៅបំផុតនៅក្នុងសម័យពេលនោះដែលគ្រូៗគឺតែងតែប្រើរំពាត់ដើម្បីដាក់វិន័យ
ឬក៏ដើម្បីប្រៀនប្រដៅសិស្ស ឬក៏វាយពេលដែលសិស្សធ្វើខុស។
អញ្ចឹងគឺក្នុងពេលនោះគឺប្រើប្រាស់រំពាត់គឺធម្មតា គឺសាមញ្ញ គឺគ្រូៗគ្រប់គ្នាជាទូទៅគឺប្រើរំពាត់
ហើយនៅក្នុងថ្នាក់រៀនគឺយើងឃើញថាលោកគ្រូ ឬក៏អ្នកគ្រូគឺតែងតែមានរំពាត់មួយ
ហើយរំពាត់នោះគឺជាទូទៅគឺធ្វើពីផ្ដៅ យើងហៅថារំពាត់ផ្ដៅ ឬក៏រំពាត់ឈើ ឬក៏ឫស្សី អញ្ចឹង
គឺជារំពាត់មួយដែលជាទូទៅរំពាត់គឺប្រើដើម្បីចង្អុលលេខ ឬអក្សរនៅលើក្ដារខៀន
អញ្ចឹងគ្រូតែងតែប្រើប្រាស់រំពាត់នេះដើម្បីចង្អុល ចង្អុលនូវអក្សរឲ្យសិស្សថាតាមពេលដែលបង្រៀន
ឬក៏គោះតុពេលដែលចង់ឲ្យសិស្សស្ដាប់ អញ្ចឹងគឺគ្រូតែងតែមានរំពាត់មួយនៅលើតុ
ហើយប្រើរំពាត់នេះដើម្បីចង្អុលលេខ ចង្អុលអក្សរ ឬក៏គោះតុ ដើម្បីឲ្យសិស្សស្ដាប់ ហើយផងដែរ
រំពាត់ក៏គ្រូប្រើរំពាត់ពេលដែល សិស្សណាធ្វើខុស ឬក៏ការដាក់វិន័យ ប្រដៅដល់សិស្ស
អញ្ចឹងនៅក្នុងថ្នាក់រៀន បើយើងមើលទៅគឺមានក្ដារខៀន
ក្ដារខៀនគឺជាបន្ទះក្ដារមួយដែលជាទូទៅគឺពណ៌ខ្មៅ ឬក៏ពណ៌ខៀវ ដែលមានទំហំប្រហែលជា ២
ម៉ែត្របណ្ដោយ [...] ១ ម៉ែត្រកន្លះទទឹង អញ្ចឹងគឺក្ដារខៀននេះ
គឺប្រើសម្រាប់សរសេរអក្សរដើម្បីបង្រៀនដល់សិស្ស អញ្ចឹងសរសេរអក្សរ ឬក៏សរសេរលេខ
ហើយសិស្សគឺចម្លងតាមក្ដារខៀន ហើយគ្រូគឺប្រើដីសដើម្បីសរសេរនៅលើក្ដារខៀន
អញ្ចឹងដីសគឺមានពណ៌ស ឬក៏ពណ៌ផ្សេងៗចំរុះពណ៌ ប៉ុន្តែជាទូទៅគឺគ្រូប្រើពណ៌ស
អញ្ចឹងហើយយើងហៅថាដីស អញ្ចឹងនៅក្នុងសម័យនោះគឺប្រើដីស
ហើយនឹងក្ដារខៀនដើម្បីសរសេរ។ ហើយគ្រូគឺមានរំពាត់ហើយចង្អុល
ដើម្បីចង្អុលអក្សរនៅក្ដារខៀនទៅដល់សិស្ស ហើយខ្ញុំចាំបានថាថ្នាក់ទី ២

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺខ្ញុំត្រូវរំពាត់មួយរំពាត់ដោយសារពេលដែលខ្ញុំមិនបានស្ដាប់គ្រូពន្យល់
ហើយខ្ញុំគឺលេងនៅក្នុងម៉ោងរៀន ដូច្នេះគឺគ្រូប្រើរំពាត់ដាក់ខ្ញុំមួយរំពាត់
ហើយធ្វើឲ្យខ្ញុំភ្ញាក់រឭក ហើយចាប់ពីពេលនោះមក
គឺខ្ញុំចាប់ផ្ដើមផ្ដោតអារម្មណ៍ទៅលើការរៀនហើយគឺមិនត្រូវលេងនៅក្នុងម៉ោងរៀនតទៅទៀតទេ។
ហើយជួយឲ្យខ្ញុំបានប្រុងប្រៀបហើយតែងតែដោយយកចិត្តទុកដាក់នៅក្នុងម៉ោងសិក្សាជានិច្ច
ហើយខ្ញុំក៏សូមបញ្ចប់ការពិពណ៌នាអំពីពេលវេលា[...]
ពេលដែលខ្ញុំរៀននៅក្នុងសាលាបឋមសិក្សានេះដោយប៉ុណ្ណេះដែរ។ សូមអរគុណ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.